**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១១៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យអនុបយោគ ទីតាំងទីស្នាក់ការក្រុមហ៊ុន កាំមីនតែល

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៩០៨ /១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០១ /១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម /០៨០៦ /៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគ

-តាមសំណើ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## សម្រេច

**មាត្រា ១ :-**

ត្រូវបានធ្វើវិសោធនកម្មមាត្រា១ នៃអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគទីតាំងស្នាក់ការក្រុមហ៊ុន កាំមីនតែល ស្ថិតនៅកែងផ្លូវព្រះស៊ីសុវត្ថិ និងផ្លូវលេខ៨៨ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដោយកែតម្រូវទំហំដី ពី ១.៩០០ ម៉ែត្រក្រឡា មកទំហំ ៣.៩០០ ម៉ែត្រក្រឡា តាមតួលេខជាក់ស្តែង ដែលកត់ត្រានៅក្នុងសាលាកប័ត្រដី នៃបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

www.pheakdeylaw.com

**មាត្រា ២ :-**

រាល់ខ្លឹមសារទាំងឡាយណានៃអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដែលមិនមានការកែតម្រូវនៅមានសុពលភាពអនុវត្ត ស្របតាមគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា ៣ :-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន កាំមីនតែល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១

បណ្ណាគារ ភក្តីឡជ
PheakdeyLaw Book Store

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>**កន្លែងទទួល**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- ឯកសារ-កាលប្បវត្តិ